# ការទទួលខុសត្រូវតឹងរឹង (Strict Liability)

១. នៅក្នុងរឿងព្រហ្មទណ្ឌ តាមគោលការណ៍ទូទៅ និងជាសកល ការដាក់ឲ្យបុគ្គលរូបណាមួយទទួលខុសត្រូវ លុះត្រាបុគ្គលនោះ បានប្រព្រឹត្តសកម្មភាព ជាមួយ ចេតនា ឬធ្វេសប្រហែសបង្កហានីយភ័យដល់ជនរងគ្រោះ ឬសង្គម។ បើតាមគោលការណ៍នីត្យានុកូលភាព ធាតុអត្តនោម័ត (ចេតនា) តម្រូវឲ្យមានការចែងក្នុងបទល្មើសព្រហ្មទណ្ឌនីមួយៗ ដែលសំដែងឡើង ដោយពាក្យ “ចេតនា” “ដឹង” ឬ “មានគោលបំណង” ជាដើម។ ឧទាហរណ៍ បទល្មើសចោរកម្ម ជនល្មើស <u>មានបំណង</u>យកទ្រព្យធ្វើជាកម្មសិទ្ធិរបស់ខ្លួន។

២. នាពេលក្រោយមក ដោយសារ ឧស្សាហកម្មរីកចំរើន ដែលហានីយភ័យនៃអំពើល្មើសក្នុងវិស័យខ្លះ បានបង្កនូវផលវិបាកធ្ងន់ធ្ងរ ដូចជា ការបំពុលបរិស្ថាន គ្រោះថ្នាក់ចរាចរ សំរាមពុល អាហារមានជាតិគីមី ច្បាប់បានចែងនូវបទល្មើសមួយចំនួន មិនទាមទារឲ្យមានធាតុផ្សំអត្តនោម័តទេ (Strict Liability Offense: SLO)។ វាជាប្រភេទបទល្មើស ហាមឃាត់ *mala prohibita* ដែលខុសពី បទល្មើសពិតប្រាកដ (real crime) ដូចជាមនុស្សឃាត *(mala in se*) ដែលមានការហាមឃាត់ និងទាមទារនូវផលវិបាកជាក់លាក់។ SLO ភាគច្រើនត្រូវចាត់ថាជាបទល្មើសស្រាល ដែលកំណត់ដោយស្ថាប័ននីតិប្រតិបត្តិ (regulatory offences) និងអនុញ្ញាតដោយសភា (មាត្រា ១ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០០៩)។ បទល្មើសប្រភេទនេះ នាំឲ្យមានការទទួលខុសត្រូវតឹងរឹង (strict liability)។

៣. SL មិនទាមទារឲ្យ រដ្ឋអាជ្ញាបង្ហាញនូវធាតុផ្សំអត្តនោម័ត ដែលនាំឲ្យអ្នកប្រព្រឹត្តទទួលខុសត្រូវទេ។ រដ្ឋអាជ្ញា គ្រាន់តែបង្ហាញនូវធាតុផ្សំសម្ភារៈ គឺជាការគ្រប់គ្រាន់ហើយ។ នេះ ខុសពីការបង្ហាញ ក្នុងការដាក់ការទទួលខុសត្រូវសម្រាប់បទល្មើសធម្មតា ដូចជា បទចោរកម្ម ដែលត្រូវបង្ហាញទាំងធាតុផ្សំសម្ភារៈ និងអត្តនោម័ត។ មានការសន្មត់ថា មានទោសជាមុន (presumption of guilty) ដែលនាំឲ្យបន្ទុកភស្តុតាង ត្រូវបានផ្ទេរទៅជនល្មើស បង្ហាញថាគាត់មិនបានប្រព្រឹត្តក្នុងកម្រិតភស្តុតាងហួសពីវិមតិសង្ស័យ (វាមិនមែនជាការបង្ហាញអំពីការដោះសារទេ)។ ទោះបីជាយ៉ាងនេះក្តី ប្រទេសខ្លះ ចែងឲ្យមានការដោះសារ ដូចជា ការព្រមទទួលនូវហានីយភ័យដោយជនរងគ្រោះ (assumption of risk)។ SL ជាការទទួលខុសត្រូវផ្ទាល់ ដែលខុសពីការទទួលខុសត្រូវជំនួស http://www.measboralaws.com/detail/1047 និងការទទួលខុសត្រូវដោយសារការធ្វេសប្រហែស (negligence)។

៤. អ្នកស្រាវជ្រាវ ឬច្បាប់ បានចាត់បទល្មើស សុខុមាលភាពសាធារណៈ (public welfare offenses) ពាក់ព័ន្ធចំណីអាហារ ឬថ្នាំពេទ្យ ចូលក្នុង SLO បន្ថែមលើបទល្មើស សេព សន្ថវៈ ជាមួយអនីតិជន ដែលស្ថិតចូលក្នុងប្រភេទនៃបទល្មើសនេះជាយូរមកហើយ។ ប្រទេសភាគច្រើន ក្នុងទ្វីបអឺរ៉ុប ដាក់ការទទួលខុសត្រូវក្នុងទម្រង់ SL ពាក់ព័ន្ធការផលិត ឬលក់ផលិតផល។

៥. នេះក្នុងគោលបំណងដើម្បីបង្កាទូវ ហានីយភ័យ ជម្រុញឲ្យអ្នកធ្វើសកម្មភាព (អ្នកផលិត) ត្រូវធ្វើការប្រយ័ត្នប្រយែងខ្ពស់។ អ្នកស្រាវជ្រាវ បានផ្អែកទៅការចំណាយ និងប្រយោជន៍ (cost and benefit) តាមទ្រឹស្តីសេដ្ឋកិច្ច និង បដិការ (reciprocity) រវាងអំពើនៃ អ្នកប្រព្រឹត្ត នឹង ផលវិបាកដែលជនរងគ្រោះទទួល។ ក្នុងអង្គហេតុដែលក្រុមហ៊ុនមួយ បានបំពុលបរិស្ថាន ការចំណាយជួសជុល អាចច្រើនជាង ផលចំណេញ ដែលក្រុមហ៊ុន ឬសង្គមទទួលបាន។ ក្នុងន័យនេះ វាទាមទារឲ្យមានការបង្កា ឬប្រុងប្រយ័ត្នជាមុននូវសកម្មភាព ដែលអាចបង្កហានីយភ័យធ្ងន់ធ្ងរ។ សម្រាប់ការអនុវត្ត ការមិនទាមទារនូវធាតុផ្សំអត្តនោម័ត នាំឲ្យតុលាការ មិនចំណាយពេលវេលាច្រើនក្នុងការដោះស្រាយសំណុំរឿង។

៦.អ្នកប្រឆាំងនឹងប្រភេទបទល្មើសប្រភេទនេះ អះអាងថា ការមិនតម្រូវឲ្យមានធាតុផ្សំអត្តនោម័ត អាចបង្កឲ្យមាន ការកាត់ទោសបុគ្គល ដែលមិនបានប្រព្រឹត្តខុសឆ្គង ហើយការសន្មត់ថា មានទោសជាមុន អាចផ្ទុយនឹងគោលការណ៍ សន្មត់ថាមិនទាន់មានទោស (Presumption of Innocence)។ តុលាការប្រទេសកាណាដា បានអះអាងថា SL បំពានធម្មនុញ្ញកាណាដា ស្តីពីសិទ្ធិមនុស្ស។

៧. ជាដំណោះស្រាយ ចៅក្រមនឹងបកស្រាយ ដោយសន្មត់ថា សភាបានដាក់ធាតុផ្សំអត្តនោម័ត ទោះបី បទល្មើសណាមួយ ត្រូវបានចែងដោយគ្មានបញ្ជាក់អំពីធាតុផ្សំប្រភេទនេះក្តី។ បន្ថែមពីលើនេះ ជម្រើសមួយចំនួនគួរត្រូវបានប្រកាន់យក៖ **ក.** ចែង SLO ដាក់ទោសស្រាល និងទាមទារនូវធាតុអត្ត នោម័តក្នុងកម្រិតទាប (civil negligence)។ **ខ.** សម្រាប់បទល្មើសមានទោសធ្ងន់ ព្រះរាជអាជ្ញាត្រូវបង្ហាញថាមានការធ្វេសប្រហែសរបស់អ្នកប្រព្រឹត្ត។ **គ.** អនុញ្ញាតឲ្យជនល្មើសលើកនូវការដោះសារ (Affirmative defence) ក្នុងកម្រិតភស្តុតាងលើសពី ៥០ ភាគរយ (balance of probability) ថាខ្លួនមិនបានប្រព្រឹត្តខុស ឬដោយសារយល់អង្គហេតុខុស (mistake of fact)។

<u>**កំណត់សំគាល់**</u>៖ មាត្រា ៦៦ នៃ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០០៥ អាចត្រូវចាត់ថាជា បទល្មើសទទួលខុសត្រូវតឹងរឹង៖ *មន្ត្រីនគរបាលចរាចរណ៍ផ្លូវគោក ត្រូវឃាត់យានជំនិះមិនឱ្យធ្វើចរាចរណ៍ ឬ*

*ឃាំងទុកយានជំនិះរយៈពេលមិនលើសពី ៣ (បី) ថ្ងៃ ដើម្បីធ្វើការពិន័យ និងកែតម្រូវលក្ខណៈបច្ចេក ទេស ទៅតាមករណីដែលអ្នកបើកបរបានប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិចរាចរណ៍ដូចខាងក្រោម ៖១...៨-យានយន្តដែលបើកបរលើសល្បឿនកំណត់ចាប់ពី ៤០ (សែសិប) គីឡូម៉ែត្រ ក្នុងមួយម៉ោងឡើងទៅ ។*

**ឯកសារយោង៖** **1**. Richard G. Singer, *Strict Liability* in Joshua Dressler, Encyclopedia of Crime and Justice, 2002, pp.1541-1546; **2**. Richard G. Singer and John Q. La Fond, Criminal Law: Example & Explanation, 2007, 117-139 and **3**. Piotr Machnikowski, ed., European Product Liability, An Analysis of the State of the Art in the Era of New Technologies, 2016.